# ប្រទេសវៀតណាមត្រូវតែប្រគល់សិទ្ធិសេរីភាពពេញលេញដល់ព្រះសង្ឃ ទឹម សាខន ឡើងវិញ
# អ្នកការពារសិទ្ធិមនុស្សបានត្រូវដោះលែងពីពន្ធនាគារ តែគេពុំដឹងថាគាត់កំពុងស្ថិតនៅទីណាឡើយ

(ពីទីក្រុងញូយ៉ក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ ២០០៨) អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) បានថ្លែងនៅថ្ងៃនេះថា ៖ អាជ្ញាធរវៀតណាមគួរតែលុបចេញជាបន្ទាន់នូវការដាក់កំរិតសេរីភាពណាមួយមកលើព្រះសង្ឃ ទឹម សាខន ដែលត្រូវបាន ដោះលែងពីពន្ធនាគារក្នុងប្រទេសវៀតណាមកាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៨ កន្លងមកនេះ។ បច្ចុប្បន្ននេះគេពុំដឹងថាតើ លោក សាខន កំពុងស្ថិតនៅទីណាឡើយ។ គេបានប្រទះឃើញគាត់ជាចុងក្រោយដោយមានការអមដំណើរ ពីមន្រ្តីរដ្ឋាភិបាលវៀតណាម។

កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ អាជ្ញាធរក្នុងប្រទេសកម្ពុជាបានចាប់ខ្លួន និងផ្សឹកព្រះសង្ឃសាខន ហើយបញ្ជូនខ្លួនគាត់ទៅកាន់ប្រទេសវៀតណាម ។ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៧ តុលាការព្រហ្មទណ្ឌក្នុងខេត្ត អាន យ៉ាងបានកាត់ទោសលោក សាខន ដាក់ពន្ធនាគាររយៈពេល១ឆ្នាំ ពីបទល្មើសបំផ្លិចបំផ្លាញឯកភាពជាតិ តាមមាត្រា៨៧នៃច្បាប់ក្រមព្រហ្មទណ្ឌវៀតណាម។ គេបានរាយការណ៍មកថា លោក សាខនពុំមានអ្នកតំណាងការពារខ្លួនតាមផ្លូវច្បាប់ឡើយ នៅក្នុងសវនាការកាត់ទោសនោះទេ ។ អង្គការសិទ្ធិមនុស្ស Human Rights Watch បាននិយាយថា ការកាត់ទោសលើរូបលោក សាខន ដោយសារហេតុផលខាងនយោបាយនេះ គឺជាការប៉ុនប៉ងបិទបាំងតិចតួចដោយរដ្ឋាភិបាលវៀតណាម និងកម្ពុជា ដើម្បីបញ្ឈប់ការតវ៉ាប្រឆាំងដោយសន្តិវិធីរបស់ជនជាតិភាគតិចខ្មែរក្រោម ដែលកំពុងតែរស់នៅក្នុងប្រទេសទាំងពីរនេះ។

លោក Brad Adams នាយកអង្គការសិទ្ធិមនុស្ស Human Rights Watch ប្រចាំទ្វីបអាស៊ីបាននិយាយថា ៖ នៅពេលដែលការដោះលែងរូបគាត់ចេញពីពន្ធនាគារ បានត្រូវគេអបអរសាទរមិនដោយចាត់ទុកគាត់ថា ជាសកម្មជនសន្តិវិធី និងជាអ្នកការពារសិទ្ធិមនុស្សនោះ លោក ទឹម សាខន មិនគួរនឹងត្រូវគេចាប់ដាក់ពន្ធនាគារ តាំងពីដំបូងនោះឡើយ ហើយឥឡូវនេះលោក សាខន គួរតែអាចមានលទ្ធភាពធ្វើដំណើរទៅកាន់ទីណា ពេលវេលាណាដែលគាត់ចង់ទៅដោយសេរី ប៉ុន្តែនៅពេលនេះ គឺនៅពុំទាន់ច្បាស់លាស់នៅឡើយទេថា គាត់ពិតជាមានសិទ្ធិសេរីភាពយ៉ាងដូច្នេះពិតប្រាកដមែននោះ។

លោក សាខន មានអាយុ ៤០ឆ្នាំ គាត់គឺជាសមាជិកម្នាក់នៃក្រុមជាតិពន្ធ ជនជាតិភាគតិចខ្មែរក្រោមម្នាក់ ដែលរស់នៅក្នុងភាគខាងត្បូងប្រទេសវៀតណាមផង និងនៅក្នុងប្រទេសកម្ពុជាផង គាត់បានបួសជាព្រះសង្ឃគង់នៅវត្តមួយស្ថិតក្នុងខេត្តតាកែវនៃប្រទេសកម្ពុជាអស់រយៈពេល១៧ឆ្នាំកន្លងមកហើយ ។ សមាជិកនៃក្រុមសហព័ន្ធខ្មែរកម្ពុជាក្រោមមួយគឺក្រុមតស៊ូមតិដែលមានមូលដ្ឋាននៅក្នុងសហរដ្ឋអាមេរិចបានអោយដឹងថា លោក សាខន បានជំរុញអោយមានការគោរពសិទ្ធិប្រជាជនខ្មែរក្រោមយ៉ាងសកម្ម

ហើយលោកក៏បានផ្តល់ទីជំរកនៅក្នុងវត្តដែលលោកគង់នៅក្នុងប្រទេសកម្ពុជាដល់ជនទេសន្តរប្រវេសន៍ ខ្មែរក្រោមមួយចំនួន និងអ្នកស្វះស្វែងរកសិទ្ធិជ្រកកោនមួយចំនួនទៀត ដែលបានរត់ចាកចេញមកពីប្រទេសវៀតណាមផងដែរ ។

ដូចបានរៀបរាប់ខាងលើនេះ ការដោះលែងលោក សាខន ចេញពីពន្ធនាគារកាលពីថ្ងៃទី២៨ ខែមិថុនាកន្លងមកបានត្រូវមន្ត្រីរដ្ឋាភិបាលអមដំណើរគាត់ទៅកាន់ស្រុកកំណើតរបស់គាត់នៅក្នុងខេត្តអាន យ៉ាងដែលអជ្ញាធរបានរៀបចំពិធីជប់លៀងមួយដើម្បីស្វាគមន៍គាត់នៅទីនោះ ។ គេបានរាយការណ៍មកថា មន្ត្រីនៅក្នុងមូលដ្ឋាននោះបានផ្តល់ដីធ្លីមួយកន្លែង និងផ្ទះដ៏ធំមួយស្ថិតនៅក្នុងខេត្ត អាន យ៉ាង ជូនលោក សា ខន ដើម្បីជាការលើកទឹកចិត្តអោយលោកបន្តស្នាក់នៅក្នុងប្រទេសវៀតណាមតទៅទៀត ។ អ្នកភូមិនានាដែលបានជួបលោក សាខន បាននិយាយថា គាត់ស្លៀកសំលៀកបំពាក់ជាជនស៊ីវិល គឺពុំមែនស្លៀកស្បង់ចីវររបស់ព្រះសង្ឃឡើយ ហើយគាត់ហាក់មានសុខភាពល្អធម្មតាទេ ។ បន្ទាប់ពីរយៈពេលតែពីរ ឬបីម៉ោងដែលគាត់ស្ថិតនៅក្នុងភូមិរួចមក អ្នកភូមិបានប្រាប់ថាមន្ត្រីរដ្ឋាភិបាលបានអមដំណើរគាត់ចាកចេញទៅកាន់ទីក្រុង ហូជីមិញ ។

លោក Adams បាននិយាយថា: បច្ចុប្បន្ននេះក្នុងពេលដែលលោក ទីម សាខនបានត្រូវដោះលែងពីពន្ធនាគារហើយនោះរដ្ឋាភិបាលវៀតណាមគួរតែផ្តល់នូវសិទ្ធិសេរីភាពពេញលេញដល់រូបគាត់ឡើងវិញ ។ គាត់គួរតែអាចមានលទ្ធភាពធ្វើដំណើរបានដោយសេរី ហើយអាចជួបជុំមិត្តភក្តិ និងក្រុមគ្រួសាររបស់គាត់បានដោយផ្ទាល់ ។ ក្នុងពេលជាមួយគ្នានេះដែរ រដ្ឋាភិបាលកម្ពុជាគួរតែធ្វើការបញ្ជាក់អះអាងជាសាធារណៈថា គាត់ក៏មានសេរីភាពនឹងវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញដែលគាត់ក៏ជាពលរដ្ឋកម្ពុជាផងដែរនោះ ។

លោក សាខន បានកើតនៅក្នុងប្រទេសវៀតណាមភាគខាងត្បូង ប៉ុន្តែគាត់បានមករស់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៨ នៅក្នុងពេលដែលគាត់ និងក្រុមគ្រួសាររបស់គាត់បានរត់គេចចេញពីការវាយប្រយុទ្ធគ្នានៅតាមព្រំដែនរវាងកងទ័ពខ្មែរក្រហម និងកងទ័ពវៀតណាម ។ ដូចគ្នានឹងសមាជិកជនជាតិខ្មែរក្រោមភាគតិចដ៏ទៃៗទៀត ដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជាដែរ លោក សាខន និងក្រុមគ្រួសាររបស់គាត់ត្រូវបានរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថាជាពលរដ្ឋកម្ពុជា ។ នៅក្នុងឆ្នាំ២០០២ ព្រះសង្ឃ សាខន បានត្រូវតំឡើងឋានៈជាព្រះចៅអធិការនៃវត្តភ្នំដិនខាងជើងក្នុងខេត្តតាកែវ ។ វាគឺជាតំណែងមួយដែលមានតែពលរដ្ឋកម្ពុជាប៉ុណ្ណោះដែលអាចទទួលបាន ដែលតំណែងនេះ តែងតាំងដោយសម្តេចព្រះមហាអគ្គសង្ឃរាជធិបតី ទេព វង្ស ។

អាជ្ញាធរកម្ពុជាបានផ្សឹកព្រះសង្ឃ សាខន នៅក្នុងទីរួមខេត្តតាកែវ កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ តាមបញ្ជារបស់សម្តេចសង្ឃ ទេព វង្ស ពីបទចោទប្រកាន់ថាបានរំលោភលើវិន័យព្រះពុទ្ធសាសនា ដោយបានធ្វើអោយខូចខាត់ដល់សាមគ្គីភាពរវាងប្រទេសវៀតណាម និងកម្ពុជា ហើយបានប្រើប្រាស់ទីវត្តអារាមដែលលោកគង់នៅដើម្បីធ្វើការឃោសនា

ផ្សព្វផ្សាយ ។ ក្រោយពីការចាប់ផ្សឹករួចមក លោក សាខន ត្រូវបានគេចាប់បង្ខំដាក់បញ្ចូលទៅក្នុងរថយន្តមួយគ្រឿងរបស់ក្រសួងមហាផ្ទៃកម្ពុជា ហើយបញ្ជូនទៅកាន់ប្រទេសវៀតណាម ជាកន្លែងដែលប៉ូលីសវៀតណាមបានចាប់ខ្លួនគាត់ពីបទឆ្លងដែនដោយខុសច្បាប់ ។ ក្រោយមកគេបានធ្វើឯកសារមួយចំនួនដោយបញ្ជាក់ថា លោក សាខន បានស្ម័គ្រចិត្តវិលត្រឡប់មកកាន់ប្រទេសវៀតណាមវិញ ។

សារពតិមានដែលគេយល់ថាស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលក្នុងប្រទេសវៀតណាមបានគូសបញ្ជាក់ថា លោក សាខនបានចែកចាយខិត្តប័ណ្ណ និងខ្សែវីដេអូ ដែលនិយាយអំពីនយោបាយ និងប្រវត្តិសាស្ត្ររបស់ខ្មែរក្រោម ញុះញង់ប្រជាជនខ្មែរក្រោមដែលរស់នៅក្នុងប្រទេសវៀតណាមអោយប្តឹងទាមទារ និងធ្វើបាតុកម្មប្រឆាំងនឹងការរឹបអូសយកដីធ្លីរបស់ពួកគេ ហើយលោក សាខន ក៏បានធ្វើជាតំណាងអោយសហព័ន្ធខ្មែរកម្ពុជាក្រោមម្នាក់នៅក្នុងប្រទេសកម្ពុជាផងដែរ ។

ក្នុងរយៈពេលប៉ុន្មានខែមុនការចាប់ខ្លួនព្រះសង្ឃ សាខន អាជ្ញាធររដ្ឋាភិបាលក្នុងប្រទេសកម្ពុជា និងវៀតណាម បានប្រឈមមុខយ៉ាងតានតឹងនឹងការកើនឡើងនៃការតវ៉ាប្រឆាំងដោយសន្តិវិធីរបស់ព្រះសង្ឃ និងកសិករខ្មែរក្រោមដែលរស់នៅក្នុងប្រទេសទាំងពីរ ដោយអំពាវនាវអោយមានការបើកអោយទូលាយថែមទៀតនូវសេរីភាពខាងសាសនា និងសិទ្ធិក្នុងការកាន់កាប់ដីធ្លី ។ អ្នកតវ៉ាប្រឆាំងទាំងនោះ ក៏បានអំពាវនាវអោយមានការដោះលែងព្រះសង្ឃខ្មែរក្រោមចំនួន៥អង្គទៀត ដែលត្រូវបានគេចាប់ដាក់ក្នុងពន្ធនាគារនៅក្នុងប្រទេសវៀតណាម បន្ទាប់ពីមានបាតុកម្មដោយសន្តិវិធីមួយ បានកើតឡើងនៅក្នុងខេត្ត សុក ត្រាង ប្រទេសវៀតណាម កាលពីខែកុម្ភៈ ឆ្នាំ២០០៧ កន្លងមក ។

ការនិរទេសខ្លួនលោក សាខន ទៅកាន់ប្រទេសវៀតណាម គឺជាការរំលោភលើច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីសញ្ជាតិរបស់កម្ពុជា ដែលបានចែងថា: ពលរដ្ឋខ្មែរនឹងមិនត្រូវបានគេចាប់បញ្ជូនខ្លួន ហើយនិរទេសទៅកាន់ប្រទេសណាមួយឡើយ លើកលែងតែមានសន្ធិសញ្ញាធ្វើបត្យាប័ននឹងគ្នាទៅវិញទៅមក ហើយដែលសន្ធិសញ្ញាធ្វើបត្យាប័នរវាងប្រទេសកម្ពុជា និងវៀតណាមនៅពុំទាន់មានឡើយ ។

អង្គការសិទ្ធិមនុស្ស Human Rights Watch ថ្លែងថា អង្គការនេះមានការព្រួយបារម្ភថា លោក សាខន អាចត្រូវបានគេកៀបសង្កត់ ឬចាប់បង្ខំអោយវិលត្រឡប់ទៅកាន់ស្រុកកំណើតរបស់លោកវិញ ដោយពុំអនុញ្ញាតអោយលោកវិលទៅកាន់ទីវត្តអារាមរបស់លោកវិញឡើយ ហើយចាប់ឃុំឃាំងលោកអោយនៅក្នុងផ្ទះដោយស្ថិតនៅក្រោមការយាមកាមរបស់ប៉ូលីស ដូចករណីការចាប់ឃុំឃាំងព្រះសង្ឃប្រឆាំងដ៏ទៃៗទៀតនៅក្នុងប្រទេសវៀតណាម ដូចជាករណីការចាប់ឃុំឃាំងអ្នកប្រឆាំងទាំងឡាយដែលមកពីព្រះវិហារព្រះពុទ្ធសាសនាដែលត្រូវបានគេហាមឃាត់នៅក្នុងប្រទេសវៀតណាមនោះ ។ តាមការការដោះលែងពីពន្ធនាគារនូវអ្នកទោសនយោបាយ និងអ្នកទោសសាសនា នៅក្នុងប្រទេសវៀតណាមខ្លះ ជួនកាលត្រូវបានគេយកទៅឃុំឃាំងនៅក្នុងផ្ទះ ឬជាការចាប់ឃុំឃាំងខ្លួនជាបណ្តោះអាសន្ន ក្នុងរយៈពេលពី១ឆ្នាំទៅ៥ឆ្នាំ ដោយ

ស្ថិតក្រោមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ ។ ក្នុងពេលរយៈពេលនោះ ពួកគេស្ថិតនៅក្រោមការឃ្លាំមើល និងការអប់រំឡើងវិញដោយមន្ត្រីមូលដ្ឋាន ហើយពួកគេត្រូវបានដកហូតសិទ្ធិខ្លះៗ ដូចជាសិទ្ធិដើរហើរ សិទ្ធិបោះឆ្នោត ឬធ្វើជាតំណាងអង្គការសាសនានានា ។

លោក Adams បានបញ្ជាក់ថា៖ ការចាប់ និងការនិរទេសលោក ទឹម សាខន គឺធ្វើឡើងខុសច្បាប់ទាំងស្រុង។ គាត់មិនគួរត្រូវបានគេចាប់ដាក់ពន្ធនាគារដោយសារតែហេតុផលនៃការជំរុញអោយមានការគោរពសិទ្ធិប្រជាពលរដ្ឋ ឬដោយសារតែការបានធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងអង្គការតស៊ូមតិអន្តរជាតិណាមួយនោះឡើយ។ ឥឡូវនេះការធានាអោយប្រាកដថា គាត់កំពុងតែមានសេរីភាពទាំងស្រុងនោះ វាគឺជាការងារជាអាទិភាពបំផុត។